# Terminal 117 Cleanup

Port of Seattle and City of Seattle

## ទិដ្ឋភាពទូទៅនៃគម្រោង

ការដ្ឋានសំអាតនៃ Terminal 117 (T-117) ដែលមានទីតាំងនៅឆ្នេរខាងលិចនៃ Lower Duwamish Waterway ក្នុង South Park គឺជាគម្រោងសំអាតរួមគ្នាមួយដោយ Port of Seattle និង City of Seattle ។ តំបន់នេះ ត្រូវបានកំណត់សំរាប់ការសំអាត ដោយសារបរិវេណដីតំបន់ខ្ពង់រាប ឆ្នេរទន្លេ និងសារធាតុកំទេចកំទីក្នុងទន្លេ ព្រមទាំងផ្នែកជាច្រើននៃទីធ្លា និងផ្លូវក្បែរៗនោះ មានកំហាប់ខ្ពស់នៃ PCBs（ប៉ូលីក្លូរីណាត ប៊ីផេនីល）ឌីអុកស៊ីន/ហ្វ៊ូរ៉ាន់ និងសារធាតុកំទេចកំទីផ្សេងទៀត ។ T-117 ត្រូវបាន កំណត់ថាជាតំបន់ចាត់ វិធានការមុន (Early Action Area - EAA) ដែលជាផ្នែកនៃតំបន់ Lower Duwamish Waterway Superfund Site ដែលបានចុះបញ្ជីដោយភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency - EPA) សហរដ្ឋអាមេរិក ស្ថិតក្រោមច្បាប់ស្តីពីការឆ្លើយតបផ្នែកបរិស្ថានទូលំទូលាយ សំណង និងការទទួលខុសត្រូវ (Comprehensive Environmental Response, Compensation and Liability Act - CERCLA) ។

នៅរដូវស្លឹកឈើជ្រុះឆ្នាំ 2010 ភ្នាក់ងារ EPA បានចេញអនុស្សារណៈស្តីពីវិធានការ (Action Memorandum) សំអាតចុងក្រោយសំរាប់តំបន់ T-117 ដោយផ្អែកតាមលទ្ធផលរកឃើញនៅក្នុងផែនការសំអាតរបស់គម្រោង (EE/CA) ។ អនុស្សារណៈស្តីពីវិធានការ កំណត់យកផែនការមួយ ដើម្បីសំអាតដីតំបន់ខ្ពង់រាប និងសារធាតុកំទេចកំទីក្នុងទន្លេ ដើម្បីកាត់បន្ថយ PCBs និងសារធាតុកំទេចកំទីផ្សេងទៀត ឱ្យទៅកាន់កម្រិតដែលនឹងការពារបរិស្ថានទន្លេ និងកាត់បន្ថយហានិភ័យសុខភាពចំពោះប្រជាជន ។ ការរៀបចំការសំអាត ឥឡូវនេះចប់សព្វគ្រប់ ហើយការដ្ឋានសំអាតត្រូវបានគ្រោងចាប់ផ្តើមក្នុងខែ មិថុនា ឆ្នាំ 2013 និងបញ្ចប់អំឡុងខែ មិថុនា ឆ្នាំ 2014 ។ សូមបន្តតាមដាន ពេលយើងខ្ញុំផ្តល់ជូនព័ត៌មានថ្មីៗ និងឱកាសចូលរួម ។